ក្រសួងអប់រំរដ្ឋ NSW

Notice of extension of suspension

Using the telephone interpreter service to contact the school

# សេចក្តីជូនដំណឹងអំពីការបន្តរយៈពេលបញ្ឈប់បណ្តោះអាសន្ន

## ការប្រើសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីទាក់ទងសាលារៀន

ឈ្មោះសិស្ស
Name of student

សូមគោរពឪពុកម្តាយ/អ្នកថែទាំ

លិខិតដែលភ្ជាប់មកជាមួយនេះ រៀបរាប់លម្អិតនៃ សេចក្តីជូនដំណឹងអំពីការបន្តរយៈពេលបញ្ឈប់បណ្តោះអាសន្ន ដែលខ្ញុំបានចេញឱ្យកូនរបស់អ្នក ដោយអនុលោមតាមគោលនយោបាយអាកប្បកិរិយាសិស្សរបស់ក្រសួងអប់រំរដ្ឋ NSW និងនីតិវិធីការបញ្ឈប់បណ្តោះអាសន្ន និងការបណ្តេញចេញ។

លិខិតនេះជូនដំណឹងអ្នកអំពីកាលបរិច្ឆេទបញ្ចប់ថ្មីនៃការបញ្ឈប់បណ្តោះអាសន្ន ហើយអញ្ជើញអ្នកឱ្យចូលរួមកិច្ចប្រជុំដំណោះស្រាយមួយ ដើម្បីពិភាក្សាអំពីការបញ្ឈប់បណ្តោះអាសន្ន និងរៀបចំផែនការសម្រាប់ការគាំទ្រនៅពេលកូនរបស់អ្នកត្រឡប់ទៅសាលារៀនវិញ។ នៅពេលសាលារៀនទាក់ទងមកអ្នក សូមប្រាប់យើងឱ្យដឹង ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់នៅឯកិច្ចប្រជុំ ហើយយើងនឹងរៀបចំជូនអ្នក។ ប្រសិនបើអ្នកមានការពិបាកយល់អំពីលិខិតដែលភ្ជាប់មកជាមួយ សូមទាក់ទងសាលារៀនដើម្បីឱ្យពួកយើងអាចពន្យល់ជូនអ្នក។

ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែផ្ទាល់មាត់ នៅពេលទាក់ទងសាលារៀន សូមហៅទូរសព្ទលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ ប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ហើយការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់ ដើម្បីជួយអ្នកក្នុងការសន្ទនា។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។

ឈ្មោះនាយកសាលា
Name of Principal

លេខទូរសព្ទរបស់នាយកសាលា
Principal's phone number